# តួនាទីអង្គការកសិករ

# ក្នុងការជួយកែលំអកម្រិតជីវភាពរស់នៅ

# របស់កសិករតាមរយៈការជំរុញនិងអនុវត្តកសិកម្ម

# សរីរាង្គនិងការសន្សំប្រាក់ដើម្បីភាពអាស្រ័យខ្លួនឯង

**សៀមរាប ថ្ងៃទី ២១-២២ ខែមិនា ឆ្នាំ២០១៧**

**បង្ហាញដោយៈ លោក សឹុ វ៉ានី (ប្រធានបណ្តាញកសិករនិងធម្មជាតិ)**

# ប្រវត្តិ

បណ្ដាញកសិករនិងធម្មជាតិ (ប.ក.ធ) បង្កើតឡើងនៅឆ្នាំ២០០៣ ហើយចុះឈ្មោះជាផ្លូវការនៅ

ក្រសួងមហាផ្ទៃ ថ្ងៃទី១០

ខែមីនា ឆ្នាំ២០០៦ ។

# ព្រឹទ្ធាចារ្យ ម៉ី សោម

# (ប្រធានក្រុមប្រឹក្សាភិបាលជឹង របស់ ប.ក.ជ)



# គោលការណ៍

ប.ក.ធ. ជាអង្គការកសិករឯករាជ្យ៖

- ឈរលើគោលការណ៍ស្ម័គ្រចិត្ត អំណាចនិងការសម្រេចចិត្តដោយកសិករ ដើម្បីកសិករ ដឹកនាំដោយកសិករ។
- មិនធ្វើនយោបាយ មិនប្រកាន់និន្នាការនយោបាយ។
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា។

# ទិសដៅ និងគោលបំណង

លើកកំពស់សេដ្ឋកិច្ចគ្រួសារកសិករ និងការអភិវឌ្ឍន៍សហគមន៍ ប្រកបដោយសមធម៌ និងនិរន្តរភាព។

គោលបំណងគឺភ្ជាប់សមាគមកសិករក្នុងប្រទេស និងអន្តរជាតិដើម្បី៖

- រួមគ្នាជាកំលាំងការពារសិទ្ធិអំណាច និងផលប្រយោជន៍កសិករ
- ចលនាផ្សព្វផ្សាយនិងលើកកំពស់កសិកម្មសរីរាង្គនៅប្រទេសកម្ពុជា

- រួមគ្នាលើកកំពស់សង្គមជនបទ  កាសហការ  និងសាមគ្គីភាពដ៏រឹងមាំរវាងកសិករនិងកសិករ  និងដៃគូពាក់ព័ន្ធ
- គាំទ្រសមាគមកសិករ  ការអភិវឌ្ឍន៍កសិកម្មនិងការគ្រប់គ្រងធនធានធម្មជាតិ
- ធានាបាននូវការសហការរវាងសមាគម  និងអង្គការកសិករជាមួយស្ថាប័នជាតិនិងអន្តរជាតិ

# បេសកកម្ម

មានឆន្ទៈខ្ពស់ដើម្បីពង្រឹងអំណាចអង្គការកសិករ តាមរយៈការជំរុញនិងលើកកំពស់ការអនុវត្ត

គំនិតថ្មី (កសិកម្មសរីរាង្គ ទីផ្សារសហគមន៍ សន្សំនិងឥណទាន និងការសហការគ្នា)។

# រចនាសម្ព័ន្ធ

ប.ក.ធ. ដឹកនាំដោយក្រុមប្រឹក្សាភិបាលជាកសិករ កើតចេញពីការបោះឆ្នោត តាមរយៈមហាសន្និបាត រាល់បីឆ្នាំម្តង ហើយគាំទ្រដោយលេខាធិការដ្ឋាន របស់បណ្តាញដែលមាន នាយកប្រតិបត្តិនិងបុគ្គលិកជំនាញ។

ហេតុផលនៃការបង្កើត ប.ក.ធ. និងការជម្រុញកសិកម្មតាមគោលការណ៍ធម្មជាតិ ៖

# កសិករនៅជនបទ៖

- មិនមានអាហារសម្រាប់ហូបចុកអោយបានពេញមួយឆ្នាំ។
- ខ្វះបទពិសោធន៍បច្ចេកទេសកសិកម្មគោលការណ៍ធម្មជាតិ។
- ខ្វះខាតដើមទុនវិនិយោគក្នុងវិស័យកសិកម្ម។
- ខ្វះជំនាញទំនាក់ទំនងលក់កសិផល។
- ខ្វះភាពជាតំណាង និងភាពជាដៃគូ។

- ខ្វះសាមគ្គីនិងការសហការគ្នាក្នុងចំណោមកសិករ។

## ពិសេសកសិករនៅជនបទមើលឃើញថា៖

- ធនធានធម្មជាតិនិងបរិស្ថានកំពុងវិចរឹល។
- ដីគីមី ថ្នាំពុលកសិកម្មគីមី និងសម្ភារៈកសិកម្មផ្សេងទៀត មានតម្លៃខ្ពស់... ។
- កសិករភាគច្រើនជាប់បំណុលគេ ទិញធាតុចូលកសិកម្ម
- ទីផ្សារនៅលើតែមាត់ឈ្មួញ។

# ខេត្ត គោលដៅរបស់ ក.ប.ធ

**ខេត្ត:** កណ្ដាល, កំពត, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, ពោធិសាត់, បន្ទាយមានជ័យ, សៀមរាប, កំពង់ធំ, កំពង់ចាម, ត្បូងឃ្មុំ, ព្រៃវែង, ស្វាយរៀង, ក្រចេះ, និងស្ទឹងត្រែង។

# ខេត្តគោលដៅរបស់ ប.ក.ជ (២០១៦)



# សមាជិកភាព ដើមទុន និង

# ភាគហ៊ុនរបស់សមាជិក ក.ប.ធ

មានសមាជិកចំនួន ៥៨.៤២៦នាក់ (ស្ត្រី៣៤.១៩៤នាក់) ក្នុង១៥ខេត្ត ៥៦ស្រុក ២១៤ឃុំ ៨០៤ភូមិ មាន៨២០ សមាគមសន្សំប្រាក់ និង ១៩ សហគមន៍កសិកម្ម។ ទុនសន្សំសរុប ១១៣,៩៤៣,១៩៦,០០០ រៀល (២៨,៤៨៥,៧៩៩ដុល្លាអាមេរិក)។ បណ្តាញមានទុន៖

1. ទ្រទ្រង់សរុប ៣,៣២៨,០០០,០០០ រៀល (៨៣២,០០០ ដុល្លាអាមេរិក)

1. ទុនសង្គម ៣២០,០១២,០០០ រៀលស្មើ៨០,០០៣ ដុល្លាអាមេរិក

2. ទុនបម្រុង ៩១,២៩២,០០០ រៀល ស្មើ២២,៨២៣ ដុល្លាអាមេរិក

យុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកទេសផលិតស្រូវ, បន្លែ, មាន់, និងត្រី តាមគោលការណ៍ធម្មជាតិ និងការអនុវត្តគំនិតថ្មី ពិសេស ប.វ.ស គឺប្រើប្រាស់រចនាសម្ព័ន្ធរបស់បណ្តាញ និងតាមរយៈអង្គការសេដាក សមាគមកសិករអាស៊ី (អាហ្វា) និងក្រសួងកសិកម្ម និងដៃគូពាក់ព័ន្ធ។

# ការកែច្នៃ និងការភ្ជាប់ផលិតផល

# ទៅកាន់ទីផ្សារ

បណ្តាញមានរោងម៉ាស៊ីនកិនស្រូវសរីរាង្គសហគមន៍ (កម្រិតស្រុក) ចំនួន៧ រួមមាន៖ ស្រុកព្រៃកប្បាស និងស្រុកបាទី (តាកែវ) ស្រុកសាមគ្គីមានជ័យ (កំពង់ឆ្នាំង) ស្រុកព្រៃឈរ (កំពង់ចាម) ស្រុកស៊ីធរកណ្តាល និង ស្រុកកំចាយមារ (ព្រៃវែង) និងស្រុកបសេដ្ឋ (កំពង់ស្ពឺ) និងម៉ាស៊ីនកិនស្រូវកណ្តាលនៅភ្នំពេញ។

- ទីផ្សារសំខាន់របស់បណ្តាញគឺ ផ្សារសហគមន៍កសិផលធម្មជាតិ (សហគ្រាសសេដាក) ដែលលក់រាយលក់ដុំ និងនាំចេញទៅបរទេស ដូចជាទីផ្សារនៅសហរដ្ឋអាមេរិក អាល្លឺម៉ង់ ហុងកុង វៀតណាម ចិន ... ។ល។
- ការភ្ជាប់ផលិតស្រូវសរីរាង្គ បន្លែ និងសាច់របស់សមាជិក ប.ក.ធ. មកកាន់ ផ្សារសហគមន៍កសិផលធម្មជាតិ គឺកសិករទទួលបានតម្លៃខ្ពស់លើសទីផ្សារសេរី ដោយកសិករចូលរួមក្នុងការសម្រេចចិត្តនិងកំណត់តម្លៃ។ លើពីនេះគឺកសិករទទួលបានប្រាក់លើកទឹកចិត្តពាណិជ្ជកម្មយុត្តិធម៌ (សហរដ្ឋអាមេរិក)។

# ការប្រឈម និង ទស្សនៈទៅអនាគត

**ការប្រឈមៈ** ការប្រឈមធំៗ៖

- កង្វះប្រព័ន្ធធារាសាស្រ្តសម្រាប់ស្រោចស្រព
- កង្វះទុនបង្វិល និងកម្ចីវិនិយោគកសិកម្មដែលមានអត្រាការប្រាក់ទាបសមរម្យ (កម្ចីធនាគារអភិវឌ្ឍន៍ជនបទ)
- ទីផ្សាររបស់សេដាកមិនមានលទ្ធភាពទទួលយកបានទាំងអស់ផលិតផលរបស់សមាជិក ប.ក.ធ។
- កង្វះបច្ចេកទេសកសិកម្ម (សេវាសាធារណៈរបស់រដ្ឋ)

## ទស្សនៈទៅអនាគត: ប.ក.ធ. នឹងខិតខំធ្វើការ៖

- បញ្ចុះបញ្ចូលរដ្ឋាភិបាលអោយបង្កើនកញ្ចប់ថវិកាវិនិយោគលើប្រព័ន្ធធារាសាស្ត្រ
- បញ្ចុះបញ្ចូលធនាគារអភិវឌ្ឍន៍ជនបទអោយផ្តល់កម្ចីទុនវិនិយោគកសិកម្មមានអត្រាការប្រាក់ទ
- ស្វែងរកទីផ្សារបន្ថែមក្រៅពីទីផ្សារសេដាកសម្រាប់ផលិតផលកសិកម្មរបស់សមាជិក

- កង្វះថាមពល ហេដ្ឋារចនាសម្ព័ន្ធ ធាតុចូលសរីរាង្គ សមត្ថភាព/បច្ចេកទេសកែឆ្នៃ និងគំនិតច្នៃប្រឌិតថ្មីៗ
- សហការជាមួយក្រសួងកសិកម្មដើម្បីទទួលបានសេវាសាធារណៈរបស់រដ្ឋ
- បង្កើនការផលិតជី/ថ្នាំសរីរាង្គ និងបច្ចេកទេសកែឆ្នៃ និងគំនិតច្នៃប្រឌិតថ្មីជួយសមាជិក។

#FAFO2016

# Asia Pacific Farmers' Forum

Supported by the Medium Term Cooperation Program Phase Two (MTCP2)



# WE ♥ YOU

Small farmers feed the world and care for the earth


ACBF
Manila 2016
WE
EFFECT
LIGHT


សន្និសីទ សារព័ត៌មាន
ទិញស្រូវកម្ពុជា ជួយកសិករកម្ពុជា
Cambodia Rice Federation


ជាតិ សាសនា ព្រះមហាក្សត្រ
ពិធីចុះហត្ថលេខា
លើអនុស្សរណៈនៃការយោគយល់
រវាង









# រោងម៉ាស៊ីនកិនស្រូវសហគមន៍
# និងការកែច្នៃអង្ករសរីរាង្គ














# ឃ្លាំងសហគមន៍ និង

# ធនាគារស្រូវសហគមន៍









# ក្រុមសន្សំប្រាក់ជួយខ្លួនឯង



# ការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ








# ការដាំបន្លែតាមគោលការណ៍ធម្មជាតិ








អរគុណច្រើនចំពោះ

ការយកចិត្តទុកដាក់

# ត្រូវចេះស្រលាញ់សាមគ្គីគ្នា

